# ការណែនាំអំពីការសម្លាប់មេរោគ សម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួន

## ការសម្លាប់មេរោគ សម្រាប់អាងត្រាំជើងប្រភេទគ្មានបំពង់នៅក្នុងហាងស្ប៉ា

**នៅពេលប្រើអាងត្រាំជើងប្រភេទគ្មានបំពង់នេះ ទឹកទាំងអស់នឹងនៅក្នុងអាងរហូត ក្នុងអំឡុងពេលនៃការផ្តល់សេវា។ សូមអនុវត្តតាមការណែនាំរបស់អ្នកផលិតអាងត្រាំជើងនេះជានិច្ច ដើម្បីសម្អាត និងការសម្លាប់មេរោគ។**

| នីតិវិធីនៃការសម្អាត និងការសម្លាប់មេរោគ | |
|---|---|
| **ជំហានទី ១** | **សម្អាត** អាងជាមួយសាប៊ូ និងទឹក។ ប្រើច្រាសរូសសម្រាប់សម្អាត។ |
| **ជំហានទី ២** | **លាងជម្រះ** ជាមួយទឹកស្អាត។ |
| **ជំហានទី ៣** | **សម្លាប់មេរោគ** ក្នុងអាងដោយសារធាតុសម្លាប់មេរោគកម្រិតមធ្យម។ បាញ់ថ្នាំឱ្យសព្វល្អ និងអនុវត្តតាមការណែនាំរបស់រោងចក្រ។ រក្សាផ្ទៃខាងលើឱ្យនៅសើម ក្នុងរយៈពេលដែលបានកំណត់ ដើម្បីឱ្យដំណើរការសម្លាប់មេរោគប្រព្រឹត្តទៅបានពេញលេញ (រយៈពេលប៉ះពាល់)។ |

### កំណត់សម្គាល់បន្ថែម

- ☑ សម្អាត និងសម្លាប់មេរោគលើតម្រង/សន្ទះ (រួមទាំងប្រភេទដែលមានមេដែក) នៅចន្លោះពេលបម្រើអតិថិជនម្នាក់ៗ។ ត្រូវដោះផ្នែកសន្ទះ screens ចេញ។
- ☑ សម្អាត និងត្រាំជក់ដុស (ដែលបានប្រើក្នុងជំហានទី ១) ក្នុងទឹកថ្នាំសម្លាប់មេរោគជារៀងរាល់ថ្ងៃ រួចទុកឱ្យវាស្ងួត។
- ☑ ប្រើតែថ្នាំសម្លាប់មេរោគដែលត្រូវបានអនុម័តដោយសុខាភិបាលកាណាដាប៉ុណ្ណោះ។
- ☑ អាចប្រើថ្នាំសម្លាប់មេរោគកម្រិតមធ្យម សម្រាប់ការសម្លាប់មេរោគក្នុងអាងត្រាំជើង ដោយអនុវត្តតាមជំហានខាងលើ។
- ☑ សូមអនុវត្តតាមការណែនាំរបស់អ្នកផលិត សម្រាប់ឧបករណ៍ និងសារធាតុសម្លាប់មេរោគទាំងអស់។
- ☑ បើប្រើទ្រនាប់៖
  - សម្អាត/សម្លាប់មេរោគក្នុងអាងទឹកនោះ ដោយប្រើថ្នាំសម្លាប់មេរោគកម្រិតស្រាលជារៀងរាល់ថ្ងៃ។
  - **បើអត់មានទ្រនាប់ ឬទ្រនាប់រហែក** សម្លាប់មេរោគដោយប្រើថ្នាំសម្លាប់មេរោគកម្រិតមធ្យម **នៅចន្លោះពេលបម្រើអតិថិជនម្នាក់ៗ។**

simcoe muskoka DISTRICT HEALTH UNIT

**Tel:** 705-721-7520
**Toll free:** 1-877-721-7520
**www.smdhu.org**